ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** **ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងព្រហ្មទណ្ឌ **នាមនាមប្រជារាស្ត្រខ្មែរ**

លេខ : ៧៦ **តុលាការកំពូល**

ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦

សាលដីកា បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៤ ខែ តុលា

លេខ : ៧៦ ឆ្នាំ ២០០៦ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៦

| | | |
|---|---|---|
| ១- ឯកឧត្តម | **ឃឹម ប៉ុណ្ណ** | ប្រធាន |
| ២- លោក | ឈឹម ស៊ីផល | ចៅក្រម |
| ៣- លោក | រឿល មួន | ចៅក្រម |
| ៤- លោក | យស់ សូខឿន | ចៅក្រមរបាយការណ៍ |
| ៥- លោក | ប៉ែន សារឿន | ចៅក្រម |

ក្រឡាបញ្ជី

លោក **ឃាង ស៊្រុន**

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ ៥១ "ខ" ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៧៦ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ របស់តុលាការកំពូល ។

***ពិបទ*** : ប្លន់ និង សមគំនិតក្នុងអំពើប្លន់ ប្រព្រឹត្តនៅភូមបារាយណ៍ ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី២១ . ២២ និងថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា០៦ និង ៦៩ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

-ជនជាប់ចោទ

១-ឈ្មោះ **អាំង ច្រឹប** "ជាចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិមាត់ខ្លា ឃុំកំពង់ឃ្លាំង ស្រុកជីក្រែង ខេត្តសៀមរាប របររកស៊ីមេផ្ទះ ទីលំនៅមុនពេលចាប់ខ្លួននៅភូមិតាវៀន ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះធូរ អាំង "ស" ម្តាយឈ្មោះឈរ ទៀង "រ" ប្តីឈ្មោះឌឹង សុខុន មានកូន០៥នាក់ ទោសពីមុនគ្មាន ។

-មានមេធាវីលោកស្រី **ពឹង ធីតា**

២-ឈ្មោះ **ហង្ស សារ៉ាត់** "ជាចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៤១ឆ្នាំ ជាតិខ្មែរ កើតនៅភូមិគោកទ្រព្យ ឃុំតាម៉ឺន ស្រុកបាត់ដំបង ខេត្តបាត់ដំបង ទីលំនៅមុនពេលចាប់ខ្លួននៅភូមិកម្មករ ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ។ ឪពុកឈ្មោះម៉ុន ហាយ "ស" ម្តាយឈ្មោះហង្ស យុន "រ" ពោះម៉ាយ មានកូន០៥នាក់ ទោសពីមុនគ្មាន ។

៣-ឈ្មោះ **ទូច អូន** ភេទស្រី អាយុ១៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិពាណិជ្ជកម្ម ឃុំរកាធំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ទីលំនៅមុនពេលចាប់ខ្លួននៅភូមិពាណិជ្ជកម្ម ឃុំរកាធំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ។ ឪពុកឈ្មោះ មួង "រ" ម្តាយឈ្មោះឆាយ គីមយី "រ" ប្តីឈ្មោះមួង ភ័ក្រ្ត មានកូន០១នាក់ ទោសពីមុនគ្មាន ។

៤-ឈ្មោះ **អឿន សាម៉ន** ភេទស្រី អាយុ១៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិពាណិជ្ជកម្ម ឃុំរកាធំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ទីលំនៅមុនពេលចាប់ខ្លួននៅភូមិពាណិជ្ជកម្ម ឃុំរកាធំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ។ ឪពុកឈ្មោះ អឿន ឆាន "រ" ម្តាយឈ្មោះមឿន "រ" ប្តីឈ្មោះឆាយ ថា មានកូន០១នាក់ ទោសពីមុនគ្មាន ។

៥-ឈ្មោះ **ហន ស៊ីណែត** ហៅ **ហន ណែត** ភេទស្រី អាយុ១៤ឆ្នាំ ជាតិខ្មែរ កើតនៅភូមិស្វាយកាល់ ឃុំសន្ទុក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ទីលំនៅមុនពេលចាប់ខ្លួននៅភូមិស្វាយកាល់ ឃុំសន្ទុក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ឪពុកឈ្មោះសៀន ខុន "ស" ម្តាយឈ្មោះមាស សុភ័ណ្ឌ ហៅ ទី "រ" នៅលីវ ទោសធ្លាប់មានតាម អំណាចសាលក្រមលេខ១៤"ក" ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៥ របស់តុលាការខេត្តសៀមរាប ឧត្តមានជ័យ ។

៦-ឈ្មោះ **មាស ណា** ភេទស្រី អាយុ១៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិស្វាយកាល់ ឃុំសន្ទុក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ទីលំនៅមុនពេលចាប់ខ្លួននៅភូមិស្វាយកាល់ ឃុំសន្ទុក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ឪពុកឈ្មោះ អឿន ឆាន "រ" ម្តាយឈ្មោះមឿន "រ" ប្តីឈ្មោះផល ហេង មានកូន០១នាក់ ទោសពីមុនគ្មាន ។

៧-ឈ្មោះ **រ៉ាត់ ចាស់** ភេទប្រុស អាយុ១៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិគោកទ្រព្យ ឃុំតាម៉ឺន ស្រុកបាត់ដំបង ខេត្តបាត់ដំបង ទីលំនៅមុនពេលចាប់ខ្លួននៅភូមិកម្មករ ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង។ ឪពុក ឈ្មោះហង្ស សារ៉ាត់ "រ" ម្តាយឈ្មោះជឹម សុខុន "ស" នៅលីវ ទោសពីមុនគ្មាន ។

៨-ឈ្មោះ **រ៉ាត់ ហ៊ុច** ហៅ **អុក** ភេទស្រី អាយុ១៣ឆ្នាំ ជាតិខ្មែរ កើតនៅ ភូមិគោកទ្រព្យ ឃុំតាម៉ឺន ស្រុកបាត់ដំបង ខេត្តបាត់ដំបង ទីលំនៅមុនពេលចាប់ខ្លួននៅភូមិកម្មករ ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ឪពុកឈ្មោះហង្ស សារ៉ាត់ "រ" ម្តាយឈ្មោះជឹម សុខុន "ស" នៅលីវ ទោសពីមុនគ្មាន ។

-មានមេធាវីលោក **ឡាយ ស៊្រី**

-ឯកឧត្តមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ "ជាម្ចាស់បណ្តឹងសាទុក្ខ" ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ពេជ្រ ពៅ ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិប្រិយ៍ថ្មី ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ទន់ ឆាយ ភេទប្រុស អាយុ៣៥ឆ្នាំ ទីលំនៅភូមិតាភុល ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។

-កាលពីថ្ងៃទី២១ . ២២ . ២៣ ខែឧសភា ឆ្នាំ២០០៥ ឈ្មោះហ៊ិន ស៊ីណាត . ឈ្មោះរ៉ាត់ ហ៊ុប . ឈ្មោះ ទូច អួន .ឈ្មោះ អឿ សាម៉ន . ឈ្មោះមាស ណា . ឈ្មោះរ៉ាត់ ចាស់ បាននាំគ្នាទៅបាយណ៍ទឹកថ្លា ដើម្បីដើរលួច លួកហោប៉ៅ យកកាបូបលុយ និងទូរស័ព្ទដៃ ពីប្រជាពលរដ្ឋដែលទៅឈរមើលគ្រោងឆ្អឹង សាកសពបុរាណ ឈ្មោះហ៊ិន ស៊ីណាត បានលួកហោប៉ៅពីប្រជាពលរដ្ឋ ០១នាក់មិនស្គាល់ឈ្មោះបានប្រាក់ ៩ម៉ឺនរៀល ឈ្មោះរ៉ាត់ ហ៊ុប "ហ" អ៊ុក បានលួកយកកាបូបលុយពីប្រជាពលរដ្ឋមិនស្គាល់ឈ្មោះបានប្រាក់ ២០០ដុល្លា ហើយបានយកប្រាក់នោះទៅឱ្យឈ្មោះអាំង ច្រឹប ជាអ្នកទទួលទុកជាមួយឪពុករបស់ខ្លួនឈ្មោះ ហង្ស សារ៉ាត់ ។ រ៉ាត់ ចាស់ បានលួច ទូរស័ព្ទចំនួន០៣គ្រឿង មិនស្គាល់ម៉ាក ពីប្រជាពលរដ្ឋម្នាក់មិនស្គាល់ ឈ្មោះ ហើយបានយកទូរស័ព្ទនោះទៅលក់នៅហាងរបស់ឈ្មោះហ៊ត់ មីនា បានតំលៃ១៦០ដុល្លា ។ ឈ្មោះ មាស ណា បានលួកហោប៉ាវពីប្រជាពលរដ្ឋម្នាក់មិនស្គាល់ឈ្មោះ បានប្រាក់៦ម៉ឺនរៀល ចំណែកឯឈ្មោះ អឿន សាម៉ន បានលួកហោប៉ាវពីប្រជាពលរដ្ឋម្នាក់មិនស្គាល់ឈ្មោះ តែមិនបានប្រាក់ ។ ឈ្មោះទូច អួន បានលួកហោប៉ៅពីប្រជាពលរដ្ឋ០១នាក់ មិនស្គាល់ឈ្មោះបានប្រាក់១០ម៉ឺនរៀល ។ ចំពេលដែលឈ្មោះ ពេជ្រ ពៅ និងប្រពន្ធឈ្មោះ Melissa បាននាំគ្នាឈរមើលគ្រោងឆ្អឹងបុរាណ ហើយត្រូវចោរលួកកាបូប លុយដែរ នៅក្នុងនោះមានម៉ាស៊ីនថត០១គ្រឿង ទូរស័ព្ទដៃ Nokia ០១គ្រឿង និងប្រាក់២៦០ដុល្លា ចំណែកឈ្មោះទន់ ឆាយ ជាប្រជាពលរដ្ឋម្នាក់ទៀត ដែលឈរមើលគ្រោងឆ្អឹងដែរនោះ ត្រូវចោរលួកយក កាបូបលុយដែរ ដែលក្នុងនោះមានប្រាក់២.០០០ដុល្លា កាតកាំម៉ុងកូ អត្តសញ្ញាប័ណ្ណ០១ និងឯកសារ មួយចំនួនទៀត ។ ក្នុងរឿងនេះឈ្មោះពេជ្រ ពៅ និង ប្រពន្ធឈ្មោះ Melissa ជងរងគ្រោះ និងជាដើម បណ្តឹងរដ្ឋប្បវេណីមិនប្តឹងទាមទារសំណងជម្ងឺចិត្តទេ ចំណែកឈ្មោះទន់ ឆាយ ប្តឹងទាមទារជម្ងឺចិត្ត ២.០០០ដុល្លា ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្តសៀមរាបថា :ចោទប្រកាន់ លើជនជាប់ចោទឈ្មោះទូច អួន .អឿន សាម៉ន . មាន ស៊ីណែត . មាស ណា . រ៉ាត់ ចាស់ . រ៉ាត់ ហុប . ហង្ស សារ៉ាត់ និងឈ្មោះអាំង ច្រឹប ពីបទ ប្លន់ និងសមគំនិតក្នុងអំពើប្លន់ ប្រព្រឹត្តទៅភូមបាយណ៍ ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី២១ . ២២ . ២៣ ខែឧសភា ឆ្នាំ២០០៥ បទល្មើស ព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា០៦ និង ៦៩ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃ បទឧក្រិដ្ឋ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១៦"គ" ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៥ របស់តុលាការ ខេត្តសៀមរាប ដែលបានសំរេច :

១-ផ្ដន្ទាទោស :

ក-ឈ្មោះ ហន ស៊ីណែត ហៅ ហន ណែត ដាក់គុកកំណត់០៦ឆ្នាំ ( ប្រាំមួយឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ។

ខ-ឈ្មោះ រ៉ាត់ ហ៊ុប ហៅ អ៊ុក ដាក់គុកកំណត់០៥ឆ្នាំ ( ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ។

គ-ឈ្មោះ ទូច អួន ដាក់គុកកំណត់០៥ឆ្នាំ ( ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ។

ឃ-ឈ្មោះ មាស ណា ដាក់គុកកំណត់ ០៥ឆ្នាំ ( ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ។

ង-ឈ្មោះ រ៉ាត់ ចាស់ ដាក់គុកកំណត់០៥ឆ្នាំ ( ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ។

ច-ឈ្មោះអឿន សាម៉ន ដាក់គុកកំណត់០៥ឆ្នាំ ( ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ។

ពីបទ : ប្លន់ ប្រព្រឹត្តនៅភូមិបារាយណ៍ ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី២១ ២២ ,២៣ ខែឧសភា ឆ្នាំ២០០៥តាមបញ្ញត្តិមាត្រា០៦ និងមាត្រា០៨នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

ឆ-ឈ្មោះហង្ស សារ៉ាត់ ដាក់គុកកំណត់០៦ឆ្នាំ ( ប្រាំមួយឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ។

ជ-ឈ្មោះ អាំង ច្រឹប ដាក់គុកកំណត់០៧ឆ្នាំ ( ប្រាំពីរឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ។

ពីបទ : សមគំនិតក្នុងអំពើប្លន់ ប្រព្រឹត្តនៅភូមិបារាយណ៍ ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី២១ , ២២ , ២៣ ខែឧសភា ឆ្នាំ២០០៥ តាមបញ្ញត្តិមាត្រា០៦ និងមាត្រា០៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ ទោស នៃបទឧក្រិដ្ឋ និងមាត្រា៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-បង្គាប់ឱ្យអាណាព្យាបាលរបស់ឈ្មោះទូច អួន ឈ្មោះហន ស៊ីណែត ឈ្មោះរ៉ាត់ ចាស់ ឈ្មោះរ៉ាត់ ហ៊ុប ព្រមទាំងឈ្មោះអាំង ច្រឹប ឈ្មោះអឿន សាម៉ន ឈ្មោះមាស ណា និងឈ្មោះហង្ស សារ៉ាត់ រួបរួមគ្នាសង ជម្ងឺចិត្តចំនួន២.០០០ដុល្លាអាមេរិក( ពីរពាន់ដុល្លា) ទៅឈ្មោះទន់ ឆាយ ជាដើមបណ្តឹងរដ្ឋប្បវេណី។ បើគ្មានប្រាក់ សងធនទណ្ឌនេះទេ ត្រូវដាក់គុកបង្ខំរូបកាយលើទណ្ឌិតឈ្មោះអាំង ច្រឹប ឈ្មោះអឿន សាម៉ន ឈ្មោះមាស ណា និងឈ្មោះហង្ស សារ៉ាត់ តាមមាត្រា០៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំរូបកាយ ។

៣-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ២០ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៥ របស់ឈ្មោះអ៊ែល វណ្ណៈ មេធាវីការពារជនជាប់ចោទឈ្មោះអាំង ច្រឹប និងបណ្តឹងឧទ្ធរណ៍លេខ២១ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៥ របស់ឈ្មោះ សួង សុភា មេធាវីការពារជនជាប់ចោទឈ្មោះ រ៉ាត់ ចាស់ , រ៉ាត់ ហ៊ុប ហៅ អ៊ុក , ទូច អួន , ហ៊ន ស៊ីណែត , អឿន សាម៉ន , មាស ណា និង ហង្ស សារ៉ាត់ ប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ១៦"គ" ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៥ របស់តុលាការខេត្តសៀមរាប លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា : សូមតម្កល់សាល ក្រមតុលាការខេត្តសៀមរាបទុកជាបានការ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៩១"ខ" ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១.ក/-ទទួលបណ្តឹងឧទ្ធរណ៍លេខ២០ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៥ របស់ឈ្មោះ អ៊ែល វណ្ណៈ ជាមេធាវីការពារជនជាប់ចោទឈ្មោះអាំង ច្រឹប ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

ខ/-ទទួលបណ្តឹងឧទ្ធរណ៍លេខ២១ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៥របស់ឈ្មោះ សួង សុភា មេធាវីការពារជនជាប់ចោទឈ្មោះ រ៉ាត់ ចាស់ , រ៉ាត់ ហ៊ុប ហៅ អ៊ុក , ទូច អួន , ហ៊ិន ស៊ីណែត, អឿន សាម៉ន , មាស ណា និង ហង្ស សារ៉ាត់ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២-ទទួលស្គាល់លោកឡាយ ស្រ៊ីវ ជាមេធាវីការពារជនជាប់ចោទ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៣-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ១៦"ក" ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៥ របស់តុលាការខេត្តសៀមរាបចោលជាអសាបង់ ។

៤-សម្រេចកែប្រែបទចោទលើជនជាប់ចោទឈ្មោះរ៉ាត់ ចាស់ , រ៉ាត់ ហ៊ុប ហៅអ៊ុក , ទូច អួន ហ៊ិន ស៊ីណែត , អឿ សាម៉ន និង មាស ណា ពីបទ ប្លន់ ប្រព្រឹត្តនៅភូមិបាកយណ៍ ឃុំទឹកវិល ស្រុកពួក ខេត្ត សៀមរាប កាលពីថ្ងៃទី២១ , ២២ និង ២៣ ខែឧសភា ឆ្នាំ២០០៥ បទល្មើសមានថែង និងផ្តន្ទាទោសតាមមាត្រា នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ទៅជាបទចោរកម្មតាមមាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលវិញ ។

៥-ផ្តន្ទាទោសជនជាប់ចោទឈ្មោះរ៉ាត់ ចាស់ , រ៉ាត់ ហ៊ុប ហៅ អ៊ុក , ទូច អួន , ហ៊ិន ស៊ីណែត អឿន សាម៉ន និង មាស ណា ដាក់ពន្ធនាគារ ក្នុងម្នាក់ៗកំណត់១៥ខែ គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៥ ពីបទចោរកម្ម ប្រព្រឹត្តនៅភូមិបាកយណ៍ ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី២១ , ២២ និង២៣ខែឧសភា ឆ្នាំ២០០៥ បទល្មើសមានថែង និងឱ្យផ្តន្ទាទោសតាមមាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៦-ឱ្យឈ្មោះអាំង ច្រឹប ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ រស់នៅមុនចាប់ខ្លួននៅភូមិតាមៀន ឃុំសាលាកម្រើក ស្រុកសៀមរាប ខេត្តសៀមរាបមុខរបរមេផ្ទះ ប្តីឈ្មោះឌិង សុខុន មានកូន០៥នាក់ ឪពុកឈ្មោះ ឈរ ទៀង "រ" ទោសពីមុនគ្មាន និងឈ្មោះ ហង្ស សារ៉ាត់ ភេទប្រុស អាយុ៤១ឆ្នាំ ជាតិខ្មែរ រស់នៅមុនចាប់ខ្លួន នៅភូមិកម្មករ ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។ ឪពុកឈ្មោះម៉ុន ហាយ "ស" ម្តាយឈ្មោះហង្ស យុន "រ" ពោះម៉ាយ មានកូន០៥នាក់ រួចផុតពីបទសមគំនិតក្នុងអំពើប្លន់ ប្រព្រឹត្តនៅភូមិបាកយណ៍ ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី២១ ,២២ និង២៣ ខែឧសភា ឆ្នាំ២០០៥ បទល្មើសមានថែង និងផ្តន្ទាទោសតាម មាត្រា៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៧-បង្គាប់ឱ្យដោះលែងឈ្មោះអាំង ច្រិប និង ហង្ស សារ៉ាត់ នេះពីពន្ធនាគារភ្លាម បើឈ្មោះ ទាំងពីរនេះមិនត្រូវបានឃុំខ្លួនពីបទអ្វីផ្សេងទៀតទេ ។

សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ១០៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៦ របស់ឯកឧត្តមអគ្គ-ព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ៥១"ខ" ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី៦ និងទី៧ នៃសេចក្តីសំរេច ។

-បានឃើញសារណា ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញា អម-សាលាឧទ្ធរណ៍ ។

-បានឃើញសារណាតប ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៦ របស់លោកឡាយ ស៊ីវ មេធាវីការពារឱ្យជនជាប់ចោទឈ្មោះហង្ស សារ៉ាត់ ( ជាចុងបណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៦របស់លោកស្រីពីង ធីតា មេធាវីការពារឱ្យជនជាប់ចោទឈ្មោះអាំង ច្រិប ( ជាចុងបណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា : សាលាឧទ្ធរណ៍សំរេចលើកលែងចោទប្រកាន់លើជនជាប់ចោទឈ្មោះអាំង ច្រិប និង ហង្ស សារ៉ាត់ ជាការត្រឹមត្រូវហើយព្រោះថា ពុំមានភស្តុតាងពីការត្រូវរ៉ូវគ្នារវាងឧទ្ទះរវាងចារី និងឈ្មោះអាំង ច្រិប ដែលជាម្ចាស់ផ្ទះជួលទេរីឯជនជាប់ចោទឈ្មោះហង្ស សារ៉ាត់ ជាឪពុក និងកូន នៃបទល្មើសនោះ តាមទម្លាប់មិនដែលចោទប្រកាន់ពីបទទទួលចោរកម្មទេ ។

សាលដីកាសាលាឧទ្ធរណ៍លេខ៥១"ខ" ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ មានលក្ខណៈត្រឹមត្រូវគម្បីតំកល់ទុកជាបានការពេញទាំងមូល ។

-បានស្តាប់ក្រឡាបញ្ជីអានបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍ នៅពេលជំនុំជំរះ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកស្រី ពីង ធីតា ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះអាំង ច្រិប "ជាចុងបណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា : កូនក្តីខ្ញុំជាម្ចាស់ផ្ទះសំរាប់ជួលឱ្យភ្ញៀវស្នាក់នៅតាមតម្លៃសមស្រប ។ ចំពោះភ្ញៀវដែលមកជួលស្នាក់នៅក្នុងផ្ទះនោះ ហើយបានប្រព្រឹត្តបទល្មើសអ្វីមួយដែលខុសច្បាប់នោះ កូនក្តីនាងខ្ញុំមិនបានដឹងឮ ឬចូលរួមធ្វើសកម្មភាពដែរ ដូចករណីឈ្មោះរ៉ាត់ ហ៊ុប ដែលបានលួចកាបូប និងប្រាក់គេ ព្រមទាំងធ្វើសកម្មភាពផ្សេងៗ នៅឆ្ងាយពីផ្ទះសុទ្ធតែជនជាប់ចោទប្រព្រឹត្ត

ខុស១គ្នា ឯលុយ១៥០ដុល្លា ជា លុយ ហង្ស សារ៉ាត់ ខ្ចីទិញម៉ូតូ កូនក្តីខ្ញុំពុំបានទទួលផលចោរកម្មនោះ ឬរឿងអ្វីឡើយ ។ រឿងនេះនៅសាលាឧទ្ធរណ៍បានសំរេចឱ្យ អាំង ច្រិប រួចផុតពីបទសមគំនិតក្នុងករណីប្លន់ ហើយដែរ ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះមេត្តាតម្កល់សាលដីកាសាលាឧទ្ធរណ៍ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ឡាយ ស៊្រីវ ជាមេធាវីការពារឱ្យជនជាប់ចោទ "ជាចុង បណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា : ចំពោះបណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ត្រង់ ចំណុចទី៦ និងទី៧ នោះ ខ្ញុំសូមឯកភាពតាមបណ្តឹងសាទុក្ខនោះដែរ តែដោយរឿងនេះនៅតុលាការខេត្ត សំរេចមានការខ្វះចន្លោះដោយផ្តន្ទាទោសពុំបានស្រាវជ្រាវល្អិតល្អន់ធ្វើការចោទប្រកាន់ខុសទាំងស្រុង ដូច ឈ្មោះហង្ស សារ៉ាត បានទៅរកកូនមិនដឹងជាកូនរបស់ខ្លួនប្រព្រឹត្តបទល្មើសអ្វីផង បែរជាចោទគាត់បទ ទទួលផលចោរកម្មដែរ ដូច្នេះរឿងនេះនៅសាលាឧទ្ធរណ៍បានកាត់ក្តីសមស្របហើយ សូមក្រុមប្រឹក្សាជំនុំ ជំរះ មេត្តាតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលជំនុំ ជំរះថា : សូមរក្សាសេចក្តីសន្និដ្ឋានរបស់ខ្លួនទុកនៅដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ និងសេចក្តីសន្និដ្ឋានរបស់ មេធាវីជនជាប់ចោទឈ្មោះអាំង ច្រិប និងមេធាវីរបស់ជនជាប់ចោទឈ្មោះហង្ស សារ៉ាត់ .

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១០៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៦ របស់ឯកឧត្តមអគ្គ ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ពុំមានភស្តុតាងណាដែលបញ្ជាក់ថា ឈ្មោះអាំង ច្រិប និងឈ្មោះហង្ស សារ៉ាត់ ថា បានពាក់ព័ន្ធ ឬបង្គាប់បញ្ជាអោយជនល្មើសធ្វើសកម្មភាពលួចប្រជាជននោះទេ ហើយការដែលឯកឧត្តម អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍អះអាងថា ពុំមានហេតុផលអ្វីដែលឈ្មោះនេះត្រូវទទួលប្រាក់ពីជន ល្មើសនោះ គ្រាន់តែជាវិមតិសង្ស័យប៉ុណ្ណោះ ហើយមានភស្តុតាងដែរថា ប្រាក់ដែលឈ្មោះនេះបានទទួលពី ឈ្មោះហង្ស សារ៉ាតនោះ គឺជាប្រាក់ថ្លៃទិញម៉ូតូទេ ។

-យល់ឃើញថា ការដែលឈ្មោះហង្ស សារ៉ាត់ ទទួលប្រាក់ពីកូននោះ ពុំអាចកំណត់បានថា ឈ្មោះ នេះជាអ្នកបង្គាប់បញ្ជាកូនរបស់ខ្លួនទៅប្រព្រឹត្តបទល្មើស ហើយក៏ពុំអាចកំណត់ថា បានទទួលផលនៃអំពើ ចោរកម្មដែរ ។

-យល់ឃើញថា ជនត្រូវចោទទាំងពីរនាក់ពុំបានមកចូលរួមសវនាការនេះទេ ប៉ុន្តែមេធាវីរបស់ជនជាប់ចោទទាំងពីរនាក់បានមកចូលរួមសវនាការនេះហើយ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៥១"ខ" ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទម្រង់ និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្ដីកំបាំងមុខជនជាប់ចោទ អាំង ច្រិប និង ហង្ស សារ៉ាត់**

**ប៉ុន្តែចាត់ទុកជាចំពោះមុខ :**

១-ទទួលបណ្ដឹងសាទុក្ខលេខ១០៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៦ របស់ឯកឧត្ដមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៥១"ច"ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៦ ។